# ធ្វើការវាយតម្លៃ EGIDS សម្រាប់ Ethnologue

Gary Simons និង Paul Lewis

ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០
កែសម្រួលចុងក្រោយ៖ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១

ក្នុងអត្ថបទស្ដីពី "Assessing language endangerment: Extending Fishman's GIDS[១]" (http://www.lingv.ro/resources/scm_images/RRL-02-2010-Lewis.pdf) ចេញផ្សាយឆ្នាំ២០១០ ពួកយើងបានបង្ហាញពី EGIDS (Extended Graded Intergenerational Disruption Scale)[២] ។ ដោយមានប្រតិកម្មជាវិជ្ជមានពីសមាជិក SIL និងអ្នកដទៃទៀត យើងគ្រោងនឹងបញ្ចូលការវាយតម្លៃកម្រិត EGIDS នេះលើភាសាទាំងអស់ក្នុងការបោះពុម្ពបន្ទាប់របស់ *Ethnologue* ។

នៅពេលដែលមានមនុស្សជាច្រើនព្យាយាមប្រើឧបករណ៍ ដើមឈើសម្រេចចិត្ត (decision tree) សម្រាប់ការវាយតម្លៃ EGIDS យើងយល់ឃើញថាការប្រើឧបករណ៍នេះរមែងតែមិនទទួលបានចម្លើយដ៏ត្រឹមត្រូវនោះទេ ។ ដូច្នេះយើងព្យាយាមកែសម្រួលនិយមន័យ និងឧបករណ៍នេះឱ្យមានភាពកាន់តែច្បាស់លាស់នៃ គំរូប្រើប្រាស់ដ៏គង់វង្ស (Sustainable Use Model)[៣] ។ យ៉ាងណាមិញ នៅពេលនេះយើងផ្ដល់វិធីសាស្ត្រជំនួយនេះសម្រាប់ការវាយតម្លៃ ។ នៅទំព័របន្ទាប់យើងនឹងឃើញតារាងកម្រិត EGIDS ដែលបានកែសម្រួល ពោលគឺ៖ កែសម្រួលនិយមន័យនៃកម្រិតមួយចំនួន ក្នុងគោលបំណងដោះស្រាយចម្ងល់ចំពោះករណីមិនច្បាស់លាស់ ។ បន្ទាប់ពីពិភាក្សាលើតារាងនៅទំព័របន្ទាប់ ហើយបើលោកអ្នកនៅមានចម្ងល់ថាតើត្រូវចែកភាសាជាក្រុមដោយវិធីណា សូមអានបទអត្ថាធិប្បាយលើកម្រិតដែលអ្នកកំពុងបែងចែកនោះ ។ ប្រសិនបើអ្នកនៅតែមិនអាចចែកចំណាត់ថ្នាក់នៃភាសានោះ សូមផ្ដល់ព័ត៌មានមកពួកយើង ។

---

[១] ការវាយតម្លៃលើភាពអន្តរាយនៃភាសា៖ ការពង្រីក GIDS របស់លោក Fishman

[២] EGIDS៖ រង្វាស់ចំណាត់ថ្នាក់ (ដែលបានពង្រីក) លើការបង្អាក់ការផ្ទេរភាសាទៅអ្នកជំនាន់ក្រោយ

[៣] Paul Lewis. THE SUSTAINABLE USE MODEL FOR LANGUAGE DEVELOPMENT. (Linguistics Dept. Colloquium, Payap University, 22 Sept. 2010)

រង្វាស់ចំណាត់ថ្នាក់ (ដែលបានពង្រីក) លើការបង្អាក់ការផ្ទេរភាសាទៅអ្នកជំនាន់ក្រោយ **(EGIDS)**
(កែសម្រួលពី Fishman ១៩៩១)

| កម្រិត | ចំណាត់ថ្នាក់ | សេចក្ដីអធិប្បាយ | UNESCO |
|---|---|---|---|
| 0 | អន្តរជាតិ | គេប្រើភាសានេះយ៉ាងទូលំទូលាយ រវាងប្រទេស និងប្រទេសក្នុងកិច្ចការជំនួញ ការផ្លាស់ប្ដូរចំណេះដឹង និងគោលនយោបាយអន្តរជាតិ ។ | សុវត្ថិភាព |
| ១ | ជាតិ | គេប្រើភាសានេះក្នុងប្រព័ន្ធអប់រំ ការងារ ប្រព័ន្ធផ្សព្វផ្សាយ និងរដ្ឋាភិបាល (ថ្នាក់ជាតិ) ។ | សុវត្ថិភាព |
| ២ | តំបន់ | គេប្រើភាសានេះក្នុងប្រព័ន្ធអប់រំ ការងារ ប្រព័ន្ធផ្សព្វផ្សាយ និងរដ្ឋាភិបាល (ថ្នាក់តំបន់) ។ | សុវត្ថិភាព |
| ៣ | ជំនួញ | គេប្រើភាសានេះក្នុងការងារ និងប្រព័ន្ធផ្សព្វផ្សាយ តែភាសានេះមិនមែនជាភាសាផ្លូវការក្នុងការដោះស្រាយភាពខុសគ្នានៃភាសាក្នុងតំបន់នោះឡើយ ។ | សុវត្ថិភាព |
| ៤ | អប់រំ | ភាសានេះមានលក្ខណៈរឹងមាំ ហើយអក្ខរកម្មនៃភាសានេះបានរីកសុសសាយតាមរយៈប្រព័ន្ធអប់រំរបស់រដ្ឋ ។ | សុវត្ថិភាព |
| ៥ | សរសេរ | ភាសានេះមានលក្ខណៈរឹងមាំ ហើយត្រូវបានប្រើយ៉ាងមានប្រសិទ្ធភាពក្នុងទម្រង់សំណេរក្នុងផ្នែកខ្លះនៃសហគមន៍ ទោះបីជាអក្ខរកម្មមិនទាន់មានភាពគង់វង្សក៏ដោយ ។ | សុវត្ថិភាព |
| ៦ក | រឹងមាំ | មនុស្សគ្រប់ជំនាន់និយាយភាសានេះ ហើយជាទូទៅក្មេងៗរៀនភាសានេះជាភាសាកំណើត ។ | សុវត្ថិភាព |
| ៦ខ | គំរាមកំហែង | មនុស្សគ្រប់ជំនាន់នៅតែនិយាយភាសានេះ តែមានសញ្ញាគំរាមកំហែងដល់ភាពគង់វង្ស ពោលគឺ៖ ការបង្អាក់ក្នុងការផ្ទេរទៅអ្នកជំនាន់ក្រោយពីចំនួនដ៏តិចតួចនៃអ្នកជំនាន់នេះដែលស្ថិតក្នុងវ័យបន្តពូជ ។ | ងាយបាត់បង់ |
| ៧ | ប្រែប្រួល | អ្នកជំនាន់នេះដែលស្ថិតក្នុងវ័យបន្តពូជអាចប្រើភាសានេះជាមួយនឹងគ្នាឯង តែជាទូទៅមិនបានផ្ទេរដល់កូនចៅនោះឡើយ ។ | អន្តរាយ |
| ៨ក | មិនលូតលាស់ | អ្នកដែលនៅនិយាយភាសានេះយ៉ាងសកម្មគឺសុទ្ធតែជាអ្នកមានវ័យចំណាស់ ។ | អន្តរាយ |

| | | | |
|---|---|---|---|
| ៨ខ | ជិតសាបសូន្យ | អ្នកដែលនៅនិយាយភាសានេះយ៉ាងសកម្មគឺមនុស្សវ័យចំណាស់ ហើយមិនសូវមានឱកាសប្រើភាសានេះទៀត ។ | អន្តរាយ |
| ៩ | អកម្ម | មិនមានអ្នកណានិយាយភាសានេះបានស្ទាត់ តែមានការប្រើប្រាស់និមិត្តសញ្ញាខ្លះនៅសេសសល់ ទុកជាកេរដំណែលនៃអត្តសញ្ញាណសម្រាប់សហគមន៍ ។ | សាបសូន្យ |
| ១០ | សាបសូន្យ | មិនមានអ្នកណារក្សាអត្តសញ្ញាណនៃជាតិសាសន៍ដែលទាក់ទងទៅនឹងភាសា សូម្បីតែជានិមិត្តរូបក៏គ្មានដែរ ។ | សាបសូន្យ |

## 0. អន្តរជាតិ

ក្នុងកម្រិតនេះយើងចាត់ទុកអង្គការសហប្រជាជាតិជាអាជ្ញាធរ ហើយស្ថាប័ននេះទទួលស្គាល់ភាសាចំនួនប្រាំមួយជាភាសាផ្លូវការរបស់អង្គការសហប្រជាជាតិ រួមមាន៖ ភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ។ យើងបញ្ចូលភាសាទាំងនេះក្នុងកម្រិតអន្តរជាតិ រីឯភាសាដទៃទៀតដែលប្រើប្រាស់ក្នុងបណ្តាប្រទេសជាច្រើន (ដូចជាភាសា ព័រទុយហ្គាល់) ចាត់ទុកជាភាសាជាតិក្នុងបណ្តាប្រទេសជាច្រើន ។

## ១. ជាតិ

សមាភាពសំខាន់នៃកម្រិត ១ គឺថាភាសាសរសេរត្រូវបានប្រើក្នុងកិច្ចការជំនួញរបស់រដ្ឋាភិបាល ។ កម្រិតនេះមិនចាំបាច់ត្រូវចែងក្នុងច្បាប់ថាជាភាសា "ផ្លូវការ" នោះទេ រីឯភាសាដែលគេនិយាយទូទាំងប្រទេស តែមិនបានប្រើក្នុងការកត់ត្រាច្បាប់ដីធ្លី ឬសាលក្រមតុលាការគឺត្រូវចាត់ចូលក្នុងកម្រិត ៣ ។

## ២. តំបន់

ដូចគ្នាទៅនឹងកម្រិត ១ លក្ខណៈចម្បងនៃកម្រិតនេះគឺគេប្រើភាសាសរសេរក្នុងកិច្ចការជំនួញរបស់រដ្ឋាភិបាល ។ ក្នុងកម្រិត ២ រដ្ឋាភិបាលមិនមែនជារដ្ឋាភិបាលថ្នាក់ជាតិ គឺត្រឹមថ្នាក់តំបន់ (ខេត្ត ឬ រដ្ឋ) ប៉ុណ្ណោះ ។

## ៣.ជំនួញ

ភាសាស្ថិតក្នុងកម្រិត ៣ មិនបានទទួលស្គាល់ជាភាសាសរសេរសម្រាប់កិច្ចការជំនួញរបស់រដ្ឋាភិបាលឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ ភាសានេះនៅតែជាភាសាទំនាក់ទំនង (vehicular)[៣] មួយដែលអ្នកនិយាយភាសាកំណើតផ្សេងៗគ្នាប្រើក្នុងកិច្ចការ ឬប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់ ។ គំរូទូទៅក្នុង EGIDS គឺថាកម្រិតនីមួយៗបន្ថែមលើអ្វីដែលពិតនៅក្នុងកម្រិតទាបជាងបន្ទាប់ នេះហើយគឺជាករណីលើកលែង ។ ក្នុងកម្រិត ៣ ភាសានោះមិនចាំបាច់ត្រូវប្រើក្នុងប្រព័ន្ធអប់រំរបស់រដ្ឋដូចក្នុងកម្រិត ៤ ឡើយ សមាសភាពចម្បងនៃកម្រិតនេះគឺការទំនាក់ទំនង (អ្នកនិយាយភាសាកំណើតផ្សេងៗគ្នាប្រើភាសានេះដើម្បីទំនាក់ទំនង) ។ គំនិតដើមដ៏សមហេតុផលរបស់ EGIDS ដែលបានកំណត់និយមន័យដោយលោក Fishman គឺថាបើកម្រិតកាន់តែល្អ ភាសានោះកាន់តែមានភាពរឹងមាំ និងមិនងាយផ្លាស់ប្តូរ ។ ច្បាស់ណាស់ថាភាសានិយាយដែលប្រើក្នុងការប្រកបរបរជំនួញ ហើយមានអ្នកប្រើរាប់លាននាក់គឺមានលក្ខណៈរឹងមាំជាងភាសាសរសេរក្នុងតំបន់ដែលមានអ្នកប្រើតែប៉ុន្មានពាន់នាក់ បើទោះបីជាភាសាសរសេរនេះទទួលបានការគាំទ្រជាផ្លូវការពីប្រព័ន្ធអប់រំរបស់រដ្ឋក៏ដោយ ។

## ៤. អប់រំ

ភាសាក្នុងកម្រិត ៤ នេះមានលក្ខណៈរឹងមាំ ហើយអាចសម្រេចបានអក្ខរកម្មជានិរន្តរ៍ តែមិនមែនជាភាសាទំនាក់ទំនងឡើយ ។ ការប្រើភាសាសរសេរក្នុងប្រព័ន្ធអប់រំគឺមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចាត់ចូលកម្រិត ៤ នោះទេ (ដូចដែលបានបង្ហាញក្នុងនិយមន័យ) ។ ផ្ទុយទៅវិញយើងគួរពិនិត្យមើលលក្ខខណ្ឌទាំងប្រាំដែលសរសេរកាត់ថា "FAMED[៤]" ក្នុងគំរូប្រើប្រាស់ដឹកដង់វង្ស ៖

- មានអក្សរសាស្ត្រនៃភាសាតំបន់សមល្មមបើធៀបទៅនឹងភាសាសរសេរនៃភាសាតំបន់ ។
- មានគ្រូជំនាញបង្ហាត់បង្រៀនអក្ខរកម្មនៃភាសាតំបន់ដោយមានការគាំទ្រពីស្ថាប័នមួយដែលមាននិរន្តរភាព ។
- សហគមន៍យល់ពីអត្ថប្រយោជន៍ផ្នែក សេដ្ឋកិច្ច សង្គម សាសនា និងអត្តសញ្ញាណក្នុងការអាន និងសរសេរភាសាក្នុងតំបន់ ។
- គោលនយោបាយរបស់រដ្ឋាភិបាលទាមទារឱ្យមានការអភិវឌ្ឍន៍ភាសានេះ ក៏ដូចជាអត្តសញ្ញាណវប្បធម៌ ហើយរដ្ឋាភិបាលបានអនុវត្តគោលនយោបាយនេះដោយទទួលស្គាល់អក្ខរាវិរុទ្ធជាផ្លូវការ ហើយប្រើប្រព័ន្ធអប់រំរបស់រដ្ឋជំរុញផ្សព្វផ្សាយអក្ខរកម្មភាសាក្នុងតំបន់ ។
- សហគមន៍មានបទដ្ឋានរួមគ្នា ពោលគឺ ៖ ពេលណាត្រូវប្រើភាសាតំបន់ក្នុងការសរសេរ ឬពេលណាត្រូវប្រើភាសាចម្បង (ដែលមានអ្នកប្រើច្រើន) ។

---

[៣] vehicular language: ភាសាទំនាក់ទំនងសម្រាប់អ្នកនិយាយភាសាកំណើតផ្សេងគ្នា ។ វាមិនមែនជាភាសាកំណើតរបស់ជាតិសាសន៍ណាឡើយ

[៤] Functions Acquisition Motivation Environment Diglossia (មុខងារ ការទទួលយក ការលើកទឹកចិត្ត បរិស្ថាន បរិបទនៃការប្រើប្រាស់ភាសា

ប្រសិនបើមិនអាចបំពេញតាមលក្ខខណ្ឌទាំងនេះ ឧទាហរណ៍ ៖ ការដកការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ការអប់រំជាភាសានោះទំនងជាបណ្តាលឱ្យមានការបោះបង់អក្ខរកម្ម ដូចនេះអក្ខរកម្មត្រូវចាត់ទុកថាទើបនឹងចាប់ផ្តើម ហើយភាសានោះក៏គួរតែចាត់ចូលកម្រិត ៥ វិញ ។

## ៥. សរសេរ

ភាសាក្នុងកម្រិត ៥ មានលក្ខណៈរឹងមាំ តែអក្ខរកម្មទើបនឹងចាប់ផ្តើម ។ ការដែលថាមានអ្នកណាម្នាក់បង្កើតប្រព័ន្ធសរសេរ ឬបោះពុម្ពអត្ថបទអក្សរសិល្ប៍គឺមិនគ្រប់គ្រាន់ក្នុងការតម្លើងពីកម្រិត ៦ក ទៅកម្រិត ៥ នោះទេ ។ ផ្ទុយទៅវិញ និយមន័យកំណត់ថាមានផ្នែកខ្លះនៃសហគមន៍ភាសាកំពុងប្រើអនុវត្តអក្ខរកម្មដោយប្រើភាសានោះបានយ៉ាងមានប្រសិទ្ធភាព ។ ប្រសិនបើនេះជាការពិត (តែការប្រើភាសានិយាយមានការគំរាមកំហែងខ្លាំង) យើងត្រូវចាត់ភាសានោះចូលក្នុងកម្រិត ៦ខ វិញ ។ ប្រសិនបើយើងមិនគិតពីកត្តាអក្ខរកម្ម យើងនឹងចាត់ភាសានេះចូលក្នុងកម្រិត ៦ខ ជាជាង ៦ក ដូចនេះការវាយតម្លៃជារួមគឺ ៦ខ ព្រោះថាភាសានេះមិនអាចចាត់ទុកថាមានលក្ខណៈរឹងមាំនោះទេ ។

## ៦ក. រឹងមាំ

ភាសាក្នុងកម្រិត ៦ក គឺជាភាសានិយាយមួយដែលរក្សាបាននូវការនិយាយជានិរន្តរ៍សម្រាប់គ្រប់ជំនាន់នៅក្នុងរង្វង់គ្រួសារ ។ សូចនាករដ៏ចម្បងនៃកម្រិតនេះគឺថាភាសាត្រូវបានផ្ទេរទៅដល់កូនចៅទាំងអស់តែក្នុងរង្វង់គ្រួសារ ។ ទោះបីជាយើងនិយាយថា "កូនចៅទាំងអស់" នេះមិនមានន័យថាអក្ខរកម្ម ១០០% នោះទេ តែនេះជាបទដ្ឋានសង្គម ហើយគេប្រើគ្រប់ៗគ្នា ។
ករណីលើកលែងខ្លះៗមិនអាចចាត់ទុកជាការគំរាមកំហែងដល់ភាពគង់វង្សនោះឡើយ ប៉ុន្តែនៅពេលមានករណីលើកលែងច្រើនលាយឡំគ្នា ហើយសហគមន៍ដឹងថាបទដ្ឋានសង្គមខ្លួននោះកំពុងតែបាត់បង់ នោះជាការគំរាមកំហែងដល់ភាពគង់វង្ស ហើយភាសានោះគួរចាត់ចូលក្នុងកម្រិត ៦ខ ។ ទោះបីជាការផ្ទេរពីអ្នកពីមួយជំនាន់ទៅមួយជំនាន់គឺជាសូចនាករចម្បងនៃកម្រិត ៦ក ក៏ដោយ តែវានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ផ្ទុយទៅវិញ យើងគួរពិនិត្យមើលលក្ខខណ្ឌ FAMED ទាំងប្រាំនៃគំរូប្រើប្រាស់ដ៏គង់វង្ស ៖

- មានការប្រើប្រាស់ភាសានិយាយគ្រប់ដែនតំបន់ (តាមចិត្តចង់) ។
- មានការផ្ទេរភាសានិយាយក្នុងតំបន់ពេញលេញដល់កូនចៅទាំងអស់ក្នុងគ្រួសារ ។
- សហគមន៍យល់ពីអត្ថប្រយោជន៍ផ្នែក សេដ្ឋកិច្ច សង្គម សាសនា និងអត្តសញ្ញាណនៃការនិយាយភាសារបស់ពួកគេ ។
- រដ្ឋាភិបាលគាំទ្រដល់ការប្រើប្រាស់ភាសានិយាយនោះ ។

- សហគមន៍មានបទដ្ឋានរួមគ្នា ពោលគឺ៖ ពេលណាត្រូវប្រើភាសាតំបន់ក្នុងការនិយាយ ឬពេលណាត្រូវប្រើភាសាចម្បង (ដែលមានអ្នកប្រើច្រើនជាង) ។

ប្រសិនបើមិនអាចបំពេញតាមលក្ខខណ្ឌទាំងនេះ ភាពគង់វង្សនៃការប្រើប្រាស់ភាសានិយាយស្ថិតក្រោមការគំរាមកំហែង ហើយភាសានោះគួរតែចាត់ចូលកម្រិត ៦ខ វិញ ។ ឧទាហរណ៍៖ ប្រសិនបើសហគមន៍យល់ដឹងតិចតួចពីតម្លៃក្នុងការប្រើភាសាតំបន់ ពួកគេនឹងចាប់ផ្ដើមផ្ទេរភាសាចម្បងទៅដល់កូនចៅ ប្រសិនបើគេបានរៀន ដូចនេះការបន្តប្រើប្រាស់ភាសាមិនអាចគង់វង្សបានទេ ហើយភាសានោះគួរចាត់ទុកក្នុងកម្រិត ៦ខ ។ ប្រសិនបើគោលនយោបាយរបស់រដ្ឋាភិបាលមិនគាំទ្រភាពចម្រុះនៃភាសា និងវប្បធម៌ ហើយធ្វើការលុបបំបាត់ ឬសង្កត់សង្កិនលើភាសានេះ ការប្រើប្រាស់ភាសាក៏មិនបានគង់វង្ស ហើយគេគួរតែចាត់ភាសានេះចូលកម្រិត ៦ខ វិញ ។

## ៦ខ. គំរាមកំហែង

ភាសាក្នុងកម្រិត ៦ខ គឺចាប់ផ្ដើមចាកផុតពីភាពគង់វង្ស ។ ប្រសិនបើមានកិច្ចខំប្រឹងប្រែងដោះស្រាយនូវលក្ខខណ្ឌខាងលើដែលកំពុងធ្វើឱ្យភាសាតំបន់ចុះអន់ថយ ភាសានោះអាចនឹងវិវដ្តត្រឡប់ទៅរកភាពគង់វង្សវិញ ។ ផ្ទុយទៅវិញបើគ្មានកិច្ចខំប្រឹងប្រែងអ្វីទាំងអស់សហគមន៍អាចនឹងបន្តផ្លាស់ប្តូរទៅប្រើភាសាចម្បងវិញ ។

## ៧. ប្រែប្រួល

ភាសាក្នុងកម្រិត ៧ គឺកំពុងតែងាកចេញពីភាពគង់វង្ស ។ ភាសានេះលែងជាបទដ្ឋានមួយដែលឪពុកម្ដាយត្រូវផ្ទេរដល់កូនចៅជំនាន់ក្រោយទៀតហើយ តែឪពុកម្ដាយនៅតែចេះភាសានេះ ដូច្នេះអាចមានការបន្តផ្ទេរទៅអ្នកជំនាន់ក្រោយ បើយើងអាចលើកទឹកចិត្តដល់សហគមន៍ឱ្យយល់ពីតម្លៃនៃភាសារបស់ពួកគេ ។ កម្រិត ៧ នេះមិនមានន័យថាការផ្ទេរភាសាដល់កូនចៅបាត់បង់ទាំងស្រុងនោះទេ តែវាគួរឱ្យកត់សម្គាល់ដែរ ។ ការផ្ទេរភាសាឱ្យបានពេញលេញកម្រនឹងធ្វើបានណាស់ ព្រោះក្មេងៗដែលកំពុងរៀនភាសានោះពិបាកនឹងរកគ្នានិយាយភាសានោះជាមួយ (រួមទាំង ស្វាមី/ភរិយា) នៅពេលធំពេញវ័យ ។

## ៨ក. មិនលូតលាស់

ភាសាក្នុងកម្រិត ៨ក គឺនៅតែមានអ្នកប្រើនៅតាមគ្រួសារខ្លះនាពេលសព្វថ្ងៃនេះ តែអ្នកដែលនៅប្រើគឺសុទ្ធតែហួសអាយុក្នុងការបង្កកំណើត ដូចនេះវដ្តនៃការផ្ទេរភាសាពីមួយជំនាន់ទៅមួយជំនាន់មិនអាចដំណើរការទៅបានដូចធម្មតានោះទេ ។ អាចមានយុវជនដែលអាចប្រើភាសានេះបានខ្លះៗ ប៉ុន្តែមិនសូវ

បាននិយាយភាសានោះជាមួយមិត្តភ័ក្តិ ដូច្នេះពួកគេក៏មិនអាចនិយាយបានស្ទាត់ជំនាញដែរ ។

## ៨ខ. ជិតសាបសូន្យ

ភាសាក្នុងកម្រិត ៨ខ មិនមានគ្រួសារនៅប្រើទៀតទេ ។ អ្នកដែលចេះភាសានេះមានប្តី/ប្រពន្ធដែលមិនចេះនិយាយភាសានេះ ដូច្នេះពួកគេមានឱកាសតិចតួចណាស់ក្នុងការប្រើភាសានេះដោយសារតែខ្សត់អ្នកប្រើពេក ។

## ៩. អកម្ម

ភាសាក្នុងកម្រិត ៩ លែងជាភាសាកំណើតរបស់ជាតិសាសន៍ណាមួយទៀតហើយ ។ យ៉ាងណាមិញភាសានេះនៅតែត្រូវចាត់ទុកជាកេរដំណែលនៃជាតិសាសន៍មួយ ហើយវានៅតែជួយរក្សាអត្តសញ្ញាណនៃជាតិសាសន៍នោះ ។ ភាសានេះនៅសេសសល់ផ្នែកខ្លះ ហើយមានការផ្ទេរផ្នែកសេសសល់ទាំងនោះដល់សហគមន៍ដើម្បីពង្រឹងអត្តសញ្ញាណដែលជាកេរដំណែលរួមមាន៖ ឈ្មោះវត្ថុ (នៃវប្បធម៌) ឈ្មោះទីកន្លែង ទំនៀមទម្លាប់ក្នុងការគោរពគ្នា របៀបប្រើភាសាក្នុងពិធីបុណ្យប្រពៃណី ឬការបន្តប្រើប្រាស់ព្រះគម្ពីរបុរាណក្នុងសហគមន៍ដែលមានជំនឿ ។

## ១០. សាបសូន្យ

ក្នុងកម្រិតនេះគេអាចស្គាល់ភាសានេះបានតាមតែឯកសារប្រវត្តិសាស្ត្រប៉ុណ្ណោះ ហើយមិនមានសហគមន៍ណាដែលយកភាសានោះធ្វើជាអត្តសញ្ញាណរបស់ខ្លួនឡើយ ។